# សិលាចារឹកប្រាសាទព្រះឥន្ទ្រកោសិយ K.២៦២ ផ្ទាំងខាងជើង (ភាគ១)

## ១- ព័ត៌មានទូទៅ

ប្រាសាទព្រះឥន្ទ្រកោសិយ ស្ថិតនៅក្នុងវត្តព្រះឥន្ទកោសីយ៍ មានទីតាំងក្នុងភូមិទ្រាំង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។ ដោយផ្អែកលើស្ថានភាពភូមិសាស្ត្រទីតាំងវត្តនេះស្ថិតនៅខាងលើនៃខ្សែទឹកហូររបស់ស្ទឹងសៀមរាប អ្នកស្រុកហៅឈ្មោះវត្តនេះថា «វត្តលើ»។ កន្លងមក AMS អរិយធម៌ខ្មែរ បានចុះផ្សាយអត្ថបទស្ដីពី «**វត្តព្រះឥន្ទ្រកោសីយ៍**» ដោយលោកបណ្ឌិត **ញឹម សុធារិទ្ធ** រួចម្ដងហើយ ដោយផ្ដោតលើស្ថានភាពទិដ្ឋភាពទូទៅនៃប្រាសាទនិងសិលាចារឹក។ លោកអ្នកអាចអានលម្អិតតាមរយៈតំណភ្ជាប់នេះ៖ https://ams.com.kh/khmercivilization/detail/6079។ អត្ថបទសិក្សាសិលាចារឹកនៅប្រាសាទនេះទាំងពីរ គឺសិលាចារឹកចុះលេខ K.២៦២ (ចារនៅលើមេទ្វារ ជាភាសាខ្មែរចំនួន ២ផ្ទាំង) និង K.២៦៣ (ចារនៅលើសសរស្ដម្ភ មាន៤មុខ ជាភាសាសំស្ក្រឹតនិងខ្មែរ) បានចុះផ្សាយជាភាសាបារាំង ដោយលោក ហ្សក សេដែស នាឆ្នាំ១៩៥២ ក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៤ ពីទំព័រទី១០៨ ដល់ទី១៣៩។ នៅក្នុងអត្ថបទនេះវិញ នឹងលើយកសិលាចារឹកដែលចារជាភាសាខ្មែរបុរាណ នៅលើមេទ្វារខាងជើងនៃប្រាសាទ មកបង្ហាញជូនលម្អិត។

ប្រាសាទនេះ នៅសល់ប្រាង្គសំខាន់ចំនួនពីរ ដែលស្ថិតនៅខាងកើតព្រះវិហារ។ ប្រាង្គខាងត្បូងជាប្រាង្គសំខាន់ មានទំហំធំ និងវិចិត្រជាងប្រាង្គខាងជើង។ ទីតាំងនេះ មានឈ្មោះបុរាណថា «**ទិជេន្ទ្របូរ**» ជាប្រាសាទព្រះនារាយណ៍ ដែលសាងឡើងដោយព្រាហ្មណ៍ឈ្មោះ «**ទិវាករភដ្ដ**» ដែលបានរៀបការជាមួយព្រះនាង «**ឥន្ទ្រលក្ស្មី**» ជាព្រះបុត្រីរបស់ព្រះបាទស្រីរាជេន្ទ្រវម៌្មទេវ។ នៅប្រាង្គខាងត្បូង មានសិលាចារឹកចារជាភាសាខ្មែរសម័យអង្គរ នៅលើមេទ្វារទាំងពីរ។ នៅលើមេទ្វារខាងជើង មានអត្ថបទចំនួន៣៥បន្ទាត់ ដែលអត្ថន័យសំខាន់គឺ នៅមហាសករាជឆ្នាំ៨៩០ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៩៦៨ មានព្រះរាជបញ្ជារបស់ព្រះមហាក្សត្រ ដែលពុំមានបញ្ជាក់ព្រះនាម ប៉ុន្តែតាមកាលបរិច្ឆេទនោះ គឺត្រូវនឹងព្រះបាទស្រីជ័យវម៌្មទេវទី៥ ទ្រង់ត្រាស់ឱ្យធ្វើបញ្ជីទេវទ្រព្យ អ្នក

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

*បម្រើ និងជីផ្ទី របស់ប្រាសាទទិវជេន្ទ្របូរ ដើម្បីប្រគល់ឱ្យស្ដេញកុលបតី។ ទេវទ្រព្យនោះពិតជាគួរឱ្យចាប់អារម្មណ៍ណាស់ ពោលគឺមានគ្រឿងកេតនភណ្ឌរបស់ព្រះនារាយណ៍ (សង្ខ ចក្រ ដំបង និងដុំផែនដី), គ្រឿងអលង្ការរបស់ប្រតិមាព្រះភគវតីរបស់ព្រះនារាយណ៍ ដែលរូបនោះក៏ជាតំណាងឱ្យព្រះនាង «**ឥន្ទ្រលក្ស្មី**», ទ្រព្យសម្បត្តិប្រើប្រាស់ក្នុងប្រាសាទ (មានដូចជា ព្រះសឡៀងសិវិកា ឆត្រ បាំងសែង ជាគ្រឿងសម្រាប់ដង្ហែទេព និងវត្ថុសម្រាប់ប្រើប្រាស់ក្នុងកិច្ចពិធីផ្សេងៗទៀតជាច្រើនមុខ) និងចុងក្រោយជាបញ្ជីឈ្មោះអ្នកបម្រើប្រុសស្រី។ អ្នកបម្រើស្រី មានមួយចំនួនមានកូនផង។ នៅខាងចុងអត្ថបទ មានបញ្ជាក់អំពីចំនួនសរុបអ្នកបម្រើក្មេងចាស់ប្រុសស្រី មានចំនួន១៧១នាក់។*

## ២- *អត្ថបទដើមជាអក្សរខ្មែរទំនើប*

*(ប.១) ៨៩០គកបូណ្ណ៍មិ[១] ជេ្យម្ពនុមានិវ្រះគាសនធូលីវ្រះបាទធូលីជេង៑ (ប.២) វ្រះកម្រតេងអញ៑បិប្រេបាញ្ជីយ[២] ទេវទ្រវ្យនុវខ្ញុំក្ញុំមា្យាករវ្រះកម្រតេ (ប.៣) ង៑អញ៑អាយទិវជេន្ទ្របុរបិប្រគល្ពតស្ដេញ៑កុលបតិ•មកុដ១ឬោតគិ១រណោមទ្វំណា១ផ្កាញ៑ (ប.៤) ២ឬោតគិ២កុន្ទុល២គង្ខ១បក្រ១គទា១ធរណី១កង្កន១មុក្តី[៣] ជុំសុវណ៌្ណករប១ឬោតគិ៩-១[៤] (ប.៥) វ្រះវសន១កដក៤ចនប្យានិ៤ឬោតគិ៤ចុរី១នៅបុរ១នាប្រាកស្នាបិករប១ស្នាបវ្រះវាសន១ (ប.៦) ស្នាបគទា១ស្នាបប្រណាល១មាត្រា១អាសន១សំវារិមាសិ១ខ្សេ្យ៤ឬោតគិ៥នាវ្រះកម្រតេងអញ៑ (ប.៧) ភគវតីយមកុដ១រណោមទ្វំណា១ផ្កាញ៑២ឬោតគិ២កុន្ទុល២កន្តី១គ្រីវត្ស១ឧទរវន្ធ១កេយូរ២កដ (ប.៨) ក២ចនិប្យានិ២ឬោតគិ២នៅបុរ២វ្រះតរា១ឬោតគិ១មាសិបំនេះ៣ឬោ១•គិរិកា១គុរុទ៤តគិគ្វេត២ (ប.៩) រត្នីវារ២កនកទន្ទ៤បតុល២០-៩ផ្កាញ៑ប្រាក២ខ្វាសិ១វៅទិប្រាកិ១វថ៌ណីហនិវ១ទ្នូទិកិហនីវ (ប.១០) ២ភាជនវារ១ភាជអ្រុង៑២ភាជនធ្មារ៦កមន្ទលូ១យជ្ជកោគ១កលគ១អឃ៌្យ១គរាវ១ខាល (ប.១១) ប្រាកិ៤អឃ៌្យបាទ្យ៦ទ្នូបោកិ១តន្ទាបិសំកូ*

---

[១] *លោក សេដែស អានជា «បូណ្ណ៍មី»។*

[២] *លោក សេដែស អានជា «បាញ្ជិយ»។*

[៣] *លោក សេដែស អានជា «មុក្តិ»។*

[៤] *លោក សេដែស ពុំអាន «១»។*

*អត្ថបទដោយៈ ហ៊ុន ឈុនតេង*

១តន្ទាបិហនិរ១តន្ទាបិ២អាទគ្គំណប្រាក់១រុប្យបតិ (ប.១២) គ្រហ១គុក្តី[៥]វតិប្រលុង១វតិធ្មារិ ១ចិវាធូប១ផ្នាបិ១អជំគង្វ១នេះស្បង់ប្រាក្ក•បទ្ម២បតុល៦ (ប.១៣) បាទ្យសោតិ២វៅទិចាំទាង[៦]ប្រាក់១វៅទីស្រះ៧តាម្រករណោ[៧]២ស្ពោក[៨]១០កទាហ១០លង្គៅជេង១ប (ប.១៤) ទិគះ៣កមន្ទលូ១អស្តារិកា១បាទលិ[៩]១ខាលបញ្ចយផ្ទ៥អយ៌្យ១គពោបិបញ្ចយផ្ទនេះស្បង់ល (ប.១៥) ង្គៅវលកា១វសិ១ថ្បង៧ខាលិបញ្ចគវ្យ៤វៅទិ១កមន្ទលូ៧ទន្ទាគ្រ២នេះស្បង់សំរិត•នោង់ចិន[១០] (ប.១៦) ៣ថ្មោបិបសិ៤ចន្ទនកំនតិ១០-៤គង្វ២តម្រេកិខ្មៅជ្បង់៥តម្រេកិសោជ្បង៥ផ្កាង្គិគ្វរនុទិកិមា (ប.១៧) ស១បនិឯងវិកដ១ទៅបនុសុម១កាម្ពទ្រវ២មញ្ជូម២០តម្រ្វាចិយោកន្ទេងយោកំបញ្ញិយោសំអ (ប.១៨) បិយោបន្ទ្វេំយោជ្រនេយិយោវ្រហ្មយោអម្ភូតយោកនិអាយោអនាយយោកំបញ្ញិយោកនិ (ប.១៩) សយោកំព្រៀយោសំអបិសោតិយោសំវាវិសោតិយោសំអបិសោតិយោថ្កេយោកន្តុរិយោ (ប.២០) ផ្នោសយោកន្សាតយោគ្រីយោថ្កោតិយោកំបុរិយោបន្ទ្វំយោវ្រហ្មយោចាំបយោធម៌្ម (ប.២១) យោកំវិតិយោកំប្រោតិយោតីថ៌យោសរាចិយោថ្ងំយោហរិយោសរាចិសោតិយោអង្គា (ប.២២) រយោថ្ប្កេកិយោបងហាងយោអថ៌ក[១១]យោថ្ប្កេកិសោតិយោសំវាវិសោតិយោបន្ទានិយោបលេ (ប.២៣) កយោអម្ភូតយោថ្ប្កេកិសោតិយោចំហោយិ[១២]•យោត្រីកូលយោអ្នន្តយោគ្រីផ្សមយោ៤០-៦តៃម (ប.២៤) ត្តញតៃកនិអក្វន[១៣]២តៃមាលតិក្វន២តៃភទ្រក្វន២តៃផ្នោសិតៃថ្នាសិក្វនិ២តៃកំបញ្ញិក្វនិ១ (ប.២៥) តៃខ្មៅក្វន១តៃកំព្រៀតៃថ្ប្កេកិតៃខ្ញុំតៃផ្ទោងតៃកនិហ្យង់ក្វនិ១តៃខ្នេតិតៃស្នុំក្វនិ៣តៃកំ (ប.២

[៥] លោក សេដែស អានជា «គុក្តិ»។

[៦] ពាក្យត្រឹមត្រូវជា «ចំទោង»។

[៧] ពាក្យត្រឹមត្រូវជា «ករណ្ឌ», អ្នកចារភ្លេចជើងឌ។

[៨] លោក សេដែស អានជា «ស្វោក»។

[៩] លោក សេដែស អានជា «បាទលី»។

[១០] លោក សេដែស អានជា «ចីន»។

[១១] លោក សេដែស ពុំអានពាក្យនេះ។

[១២] លោក សេដែស ពុំអានពាក្យនេះ។

[១៣] លោក សេដែស អានជា «តៃកនិអក្វន»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៦) វ្នកតៃកញ្ចុងតៃកនិរៅតៃសំអបិតៃគ្រម្ពតៃកំប្រ្វាតិតៃលងវេងតៃកំបិតិក្ញ្ចនិ២តៃប្រា (ប.២៧) ក្ញនិ១តៃសំអបិសោតិក្ញនិ២តៃបំនងក្ញនិ៣តៃប្ញ៉ៃក្ញនិ១តៃកនិរុនិតៃកន្សេវាតៃបន្ទានិតៃកនិអាតៃ (ប.២៨) --តៃស្រវេងតៃខ្លួសោតិតៃកញ្ញានិតៃកំព្រាំតៃកញ្ចនិតៃបវិត្រតៃកំវៃតៃភាជនតៃកលអ (ប.២៩) ហតៃខ្ញុំវ្រះតៃចាម្បតៃកនិរៅតៃកន្ទេងតៃផ្លុំតៃវ្រហ្មតៃកំភាចិតៃកន្ដ្ដំតៃលង្គាយិតៃពោទ្រ្វតៃ (ប.៣០) កន្ត្ដំសោតិតៃកញ្ញាតៃកំប្រ្វាតិតៃភារតីក្ញន២[១៤]តៃកនិរៅសោតិក្ញនិ២[១៥]តៃបន្ទានិក្ញន៣តៃកំព្រៀក្ញ (ប.៣១) ន២តៃមិមិះ[១៦]តៃលបិះតៃកំវងតៃកន្សេវាក្ញនិ១តៃសហេតុតៃបេលិតៃទវិតិតៃកំវៃក្ញនិ១•តៃឆ្មោ (ប.៣២) ងតៃបវោងតៃកំប្រ្វាតិក្ញនិ១តៃថ្ប្យកិក្ញនិ២តៃឆ្នែ[១៧]តៃភាជនក្ញន១តៃកំបិតិក្ញនិ២តៃខ្មៅក្ញន១ (ប.៣៣) តៃកំព្រៀក្ញនិ២តៃបន្ទានិក្ញនិ២តៃកំប្រ្វាតិសោតិផ្សមតៃ៦០-១០-៦ផ្សប[១៨]ក្ញន៤០-១ឃោធម្មឃោកំ (ប.៣៤) ក្ញឃោគ្រម្ពឃោកន្សាតិឃោសរាចិឃោអម្វុតឃោកញ្ចុនិឃោថ្ប្យកិផ្សម៨ផ្សំផ្ទោង (ប.៣៥) សវាលវ្វទ្ធ១០០-៦០-១០-១៙

## ៣- អត្ថបទប្រែសម្រួល

(១-៣) មហាសករាជឆ្នាំ៨៩០ ពេញបូណ៌មី ខែជេស្ឋ នូវមានព្រះរាជសាសន៍នៃធូលីជើងព្រះគម្តែងអញ គប្បីប្រើឱ្យចុះបញ្ជីទេវទ្រព្យ ខ្ញុំបម្រើ និងភូម្យាករព្រះគម្តែងអញនៅទ្វិជេន្ទ្របុរ ដើម្បីប្រគល់ដល់ស្តេញកុលបតី[១៩]។

(៣-៦) មកុដ១(ដាំ)ត្បូងថ្ម១(គ្រាប់) ដំបងចម្បាំង១ ជន្ទួញ២(ដាំ)ត្បូងថ្ម២(គ្រាប់) ក្រវិលទុំហូ២ សង្ខ១ ចក្រ១ ដំបង១ ដុំធរណី១ កងកន់១ ក្រោះមាសដាំកែវមុក្តាជុំ១(ដាំ)ត្បូងថ្ម៩

[១៤] លោក សេដែស អានជា «១»។

[១៥] លោក សេដែស អានជា «៣»។

[១៦] លោក សេដែស អានជា «មិមិះ»។

[១៧] លោក សេដែស អានជា «ឆ្មែ»។

[១៨] ពាក្យត្រឹមត្រូវជា «ផ្សម»។ លោក សេដែស អានជា «ផ្សម» ប៉ុន្តែនៅលើថ្មឃើញច្បាស់ជា «ផ្សប» គឺអ្នកចារភ្លេចសញ្ញាវះពោះ។

[១៩] គឺស្តេញដែលជាម្ចាស់ឬអ្នកគ្រប់គ្រងត្រកូលឬប្រាសាទ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

(គ្រាប់ចំនួន)១ ព្រះពស្ត្រ១ ខ្សែដៃកដក១ ចិញ្ចៀន៤(ដាំ)ត្បូងថ្ម៤(គ្រាប់) កាំបិតស្នៀតចុរី១ ចង្រ្កង់ជើង១។ វត្ថុ(ធ្វើពី)ប្រាក់(មាន)៖ ស្នាប់ក្រោះ១ ស្នាប់ព្រះពស្ត្រ១ ស្នាប់ដំបង១ ស្នាប់ស្ពានទ្រទានី១ ក្រវិលមាត្រា១ អាសនៈ១ សង្វារមាស១ ខ្សែ៤(ដាំ)ត្បូងថ្ម៥(គ្រាប់)។

(៦-៨) (ទ្រព្យ)នា(ប្រាសាទ)ព្រះកម្តែងអញកគវតី(មាន) មកុដ១ ដំបងចម្បាំង១ ជន្ទួញ២(ដាំ)ត្បូងថ្ម២(គ្រាប់) ក្រវិលទុំហូ២ ខ្សែក១ អលង្ការស្រីវត្ស១ ក្រវាត់ទ្រូង១ កងដៃ២ ខ្សែដៃ២ ចិញ្ចៀន២(ដាំ)ត្បូងថ្ម២ ចង្រ្កង់ជើង២ ព្រះតព១(ដាំ)ត្បូថ្ម១(គ្រាប់) មាសពបំនេះត្បូងថ្ម១(គ្រាប់)។

(៨-១៧) ព្រះសលៀងសិរិកា១ (មានរូប)គ្រុឌ៤ និងស្វេត(ឆត្រ)២(ដើម) ប៉ាំងសែង២ ដំបងមាស៤(ដើម) ហឹប២៩ ជន្ទួញប្រាក់២ កន្ទាស់១ ថូវៅទិប្រាក់១ ថូវថៃណី(ធ្វើពី)ហានិរ១ នូទឹក(ធ្វើពី)ហានិរ២ ភាជន៍វារ១ ភាជន៍ធំ១ ភាជន៍តូច១ ថូកមណ្ឌលូ១ គម្របយជ្ញ១ ថូក្ទស់១ ថូអឃ៌្យ១ ស្រាពក៍១ ផ្តិតខាលប្រាក់៤ ថូអឃ៌្យមានជើង(ចំនួន)៦ ផ្តិលបណ្តែត១ តន្ទាប់សំក្ទ[20]១ តន្ទាប់ហានិរ១ តន្ទាប់២ កញ្ចក់ប្រាក់១ កន្តោរស្តោះប្រាក់១ (ខ្សែ)ក្រវាត់សុក្តីធំ១ (ខ្សែ)ក្រវាត់(សុក្តី)តូច១ (ថូ)ចិព(សម្រាប់ដោត)ធូប១ ក្រចាប់១ អឌ្ឍសង្ខ១។ ទាំងនេះសឹងតែជាប្រាក់។ ផ្កាឈូក២ ហឹប៦ (និងហឹប)មានជើង២ទៀត ថូវៅទិជំទង់(ធ្វើពី)ប្រាក់១ ថូវៅទីរលោង៧ ប្រអប់ស្ពាន់២ ស្តោក១០ ខ្វះ១០(ធ្វើពី)ស្ពាន់(ចំនួន)១ជើង កន្តោរស្តោះ៣ ថូកមណ្ឌលូ១ ប្រអប់អស្តារិកា១ បាទលី១ ខាល(សម្រាប់ធ្វើ)បញ្ចយជ្ញ៥ ថូអឃ៌្យ១ គម្របបញ្ចយជ្ញ(១)។ ទាំងនេះសឹងតែជាស្ពាន់។ វលកា១ ពស់១(ដាំ)ត្បូង៧(គ្រាប់) ខាលបញ្ចគវ្យ៤ ថូវៅទិ១ ថូកមណ្ឌលូ៧ ដំបងធំ២។ ទាំងនេះសឹងតែជាសំរឹត។ នោងចិន៣ ថ្មបស់៤ ខ្លឹមចន្ទន៍១៤ កំណាត់ សង្ខ២ លោហៈតម្រេកខ្មៅ៥ជញ្ជីង តម្រេកស៥ជញ្ជីង រប៉ាំងគូសទឹកមាស១ វត្ថុសម្រាប់បែងមានប្រវែងវែង១ ក្រណាត់ទោបមានផ្កា១ ឈើស្ទន់២ មញ្ជូសា២។

(១៧-៣៥) តម្រួត(មាន) ឃោ[21]កន្ទេង ឃោកំបញ់ ឃោសំអប់ ឃោបន្ទើម ឃោជ្រនើយ ឃោព្រហ្ម ឃោអម្ទួត ឃោកន្អា ឃោអនាយ ឃោកំបញ់ ឃោកន្សែ ឃោកំព្រៅ ឃោសំអប់

[20] តន្ទាប់ធ្វើពីលោហៈពណ៌ស។

[21] «ឃោ» សម្គាល់មនុស្សប្រុសមានកម្លាំង។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

*ម្នាក់ទៀត ឃោសំរាវម្នាត់ទៀត ឃោសំអប់ម្នាក់ផ្សេងទៀត ឃោថ្កេ ឃោកណ្ដុរ ឃោផ្ទោស ឃោកន្សាត ឃោស្រី ឃោថ្កោត ឃោកំបុរ ឃោបន្ទើម ឃោព្រហ្ម ឃោចាំប ឃោធម៌្ម ឃោកំពិត ឃោកំប្រោត ឃោតីថ៌ ឃោសរាច ឃោថ្ងើម ឃោហរិ ឃោសរាចម្នាក់ទៀត ឃោអង្គារ ឃោផ្សុក ឃោបង្ហាង ឃោអថ៌ក ឃោផ្សុកម្នាក់ទៀត ឃោសំរាវម្នាក់ទៀត ឃោបន្ទាន់ ឃោបលេក ឃោអម្ទូត ឃោផ្សុកម្នាក់ទៀត ឃោចំហោយ ឃោត្រីកូល ឃោអន្ទ្ត ឃោស្រី សរុបមនុស្សប្រុស៤៦(នាក់)។ (នារីមាន) តៃ[២២]មត្តញ តៃកន្ទុក កូន២នាក់ តៃមាលតីកូន២នាក់ តៃកទ្រ កូន២នាក់ តៃផ្ទោស តៃថ្នាសកូន២នាក់ តៃកំបញ់ កូន១នាក់ តៃខ្មៅកូន១នាក់ តៃកំព្រៅ តៃផ្សុក តៃខ្ញុំ តៃច្បង តៃកន្លុង កូន១នាក់ តៃខ្នើត តៃស្នុំ កូន៣នាក់ តៃកំព្រឹក តៃកញ្ចុង តៃកន្ទ្រោ តៃសំអប់ តៃស្រេស្ឋ តៃកំប្រ្វាត តៃលង្វែង តៃកំបិត កូន២នាក់ តៃប្រាណ កូន១នាក់ តៃសំអប់ម្នាក់ទៀត កូន២នាក់ តៃបំនង កូន៣នាក់ តៃថ្ងើម កូន១នាក់ តៃកទ្រុន តៃកន្សោ តៃបន្ទាន់ តៃកន្ទា តៃ-- តៃស្រង៉ែ តៃខ្ចូម្នាក់ទៀត តៃកញ្ចាន់ តៃកំព្រាំ តៃកញ្ចន់ តៃបពិត្រ តៃកំវៃ តៃភាជន តៃកលអហ តៃខ្ញុំវ្រះ តៃចាម្ប តៃកន្ទ្រោ តៃកន្ទេង តៃផ្អែម តៃព្រហ្ម តៃកំភាច តៃកណ្ដើម តៃលង្គាយ តៃរោទ្រ តៃកណ្ដើមម្នាក់ទៀត តៃកញ្ចា តៃកំប្រ្វាត តៃភារតី កូន២នាក់ តៃកន្ទ្រោម្នាក់ទៀត កូន២នាក់ តៃបន្ទាន់ កូន៣នាក់ តៃកំព្រៅ កូន២ តៃមិសិះ តៃលបិះ តៃកំពង់ តៃកន្សោ កូន១នាក់ តៃសហេតុ តៃបេល តៃទរិត តៃកំវៃ កូន១នាក់ តៃច្បង តៃបរោង តៃកំប្រ្វាត កូន១នាក់ តៃផ្សុក កូន២នាក់ តៃឆ្មើម តៃភាជន កូន១នាក់ តៃកំបិត កូន២នាក់ តៃខ្មៅ កូន១នាក់ តៃកំព្រៅ កូន២នាក់ តៃបន្ទាន់ កូន២នាក់ តៃកំប្រ្វាតម្នាក់ទៀត។ សរុបនារី ៧៦នាក់ សរុបកូន ៤១នាក់។ ឃោធម៌្ម ឃោកំភូ ឃោស្រេស្ឋ ឃោកន្សាត ឃោសរាច ឃោអម្ទូត ឃោកញ្ចុន ឃោផ្សុក សរុប៨នាក់។ សរុបទាំងអស់ ទាំងក្មេងចាស់ ១៧១នាក់។*

---

[២២] *«តៃ» សម្គាល់មនុស្សស្រី។*

## បញ្ជីឯកសារ

Cœdès, George. (1952). Inscriptions du Vat Práḥ Ĕinkosĕi. In *Inscription du Cambodge* (Vol. IV, pp. 108-139). Paris: Editions de Boccard.

## បញ្ជីរូបភាព



ប្រាសាទព្រះឥន្ទ្រកោសិយ (រូបថតៈ រឿន សោម)




ប្រាសាទព្រះឥន្ទ្រកោសិយ (រូបថតៈ រឿន សោម)

អត្ថបទដោយៈ ហ៊ិន ឈុនតេង



ហោជាងនិងផ្តែរប្រាសាទព្រះឥន្ទ្រកោសិយ



សិលាចារឹកប្រាសាទព្រះឥន្ទ្រកោសិយ K.២៦២ មេទ្វារខាងជើង

អត្ថបទដោយៈ ហ៊ុន ឈុនតេង



សិលាចារឹកប្រាសាទព្រះឥន្ទ្រកោសិយ K.៦៦២ មេទ្វារខាងជើង



សិលាចារឹកប្រាសាទព្រះឥន្ទ្រកោសិយ K.៦៦២ មេទ្វារខាងជើង

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សិលាចារឹកប្រាសាទព្រះឥន្ទ្រកោសិយ K.២៦២ មេទ្វារខាងជើង



សិលាចារឹកប្រាសាទព្រះឥន្ទ្រកោសិយ K.២៦២ មេទ្វារខាងជើង

អត្ថបទដោយៈ ហ៊ុន ឈុនតេង



អត្ថទចម្លងសិលាចារឹកប្រាសាទព្រះឥន្ទ្រកោសិយ K.២៦២ មេទ្វារខាងជើង

អត្ថបទដោយៈ ហ៊ុន ឈុនតេង